CAMBODIAN

សន្លឹកព័ត៌មានពិត

# យើង ♥ ទីក្រុងស៊ីថលភាគអាគ្នេយ៍

## ការកែលម្អសុវត្ថិភាពថ្មីនឹងមកដល់ផ្លូវ Rainier Ave S

និទាឃរដូវឆ្នាំ ២០១៨

### ទិដ្ឋភាពទូទៅនៃគម្រោង

នៅឆ្នាំ ២០១៤ យើងបានចាប់ផ្ដើមសកម្មភាពនៃគម្រោងកែលម្អផ្លូវ Rainier Ave S ( Rainier Ave S Corridor Improvements Project ) ដើម្បីពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃសុវត្ថិភាពតាមដងផ្លូវ Rainier Avenue S ដែលស្ថិតនៅចន្លោះវិថី S Alaska St និងវិថី S Henderson St ។ គោលបំណងរបស់យើងគឺដើម្បី ៖

- កាត់បន្ថយល្បឿនជាមធ្យមរបស់យានយន្ត និងគ្រោះថ្នាក់នៃការបើកបរហួសល្បឿនកំណត់
- កាត់បន្ថយចំនួនមនុស្សដែលមានរបួសធ្ងន់ធ្ងរ ឬមនុស្សស្លាប់ដោយសាររថយន្តបុកគ្នា
- កែលម្អផ្លូវប្រសព្វ
- រក្សាប្រសិទ្ធភាព និងការជឿជាក់លើសេវារបស់រថយន្តក្រុង

គម្រោងនេះគឺជាផ្នែកមួយនៃកម្មវិធី Vision Zero របស់ទីក្រុងស៊ីថល ដើម្បីសម្រេចគោលដៅមិនឲ្យមានមនុស្សស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ឬមនុស្សរងរបួសធ្ងន់ធ្ងរ ឲ្យបានត្រឹមឆ្នាំ ២០៣០ ។ យើងកំពុងរៀបចំគម្រោងនេះរួមជាមួយគម្រោង RapidRide Rainier ដើម្បីរក្សាប្រសិទ្ធភាព និងការជឿជាក់លើសេវារបស់រថយន្តក្រុង ហើយក្នុងពេលជាមួយគ្នានេះយើងក៏កំពុងបង្កើនសុវត្ថិភាពតាមដងផ្លូវ Rainier Ave S ផងដែរ ។



ថ្ងៃនេះ




បន្ទាប់ពីការសាងសង់ (រដូវស្លឹកឈើជ្រុះឆ្នាំ ២០១៨)

### ការកែលម្អនាពេលអនាគត

នៅឆ្នាំ ២០១៥ យើងបានបញ្ចប់ដំណាក់កាលទី ១ នៃគម្រោងនេះ នៅក្នុងនោះយើងបានកែលម្អវិថី Rainier Ave S ដែលស្ថិតនៅចន្លោះវិថី S Alaska St និង វិថី S Kenny St ដោយកែច្នៃផ្លូវបើកបរពី ៤ ផ្លូវទៅជា ៣ ផ្លូវវិញ ។ នៅឆ្នាំ ២០១៧ យើងបានស្នើសុំគំនិតរបស់អ្នកចំពោះផែនការកែលម្អចំនួន ២ សម្រាប់ដំណាក់កាលទី ២ នៃគម្រោងនេះ ពោលគឺគម្រោងកែលម្អកំណាត់ផ្លូវចាប់ពីវិថី S Kenny St ទៅដល់វិថី S Henderson St ។ ក្នុងចំណោមគំនិតល្អៗទាំងឡាយនោះ យើងបានរកឃើញគំនិតរួមធំៗចំនួន ២ ពោលគឺ ការគាំទ្រឲ្យមានការសាងសង់ផ្លូវកណ្ដាលមួយសម្រាប់ការបត់ក្រោយ និងការចង់បានសេវារថយន្តក្រុងរបស់ខ្សែ Metro Route 7 ដែលដំណើរការញឹកញាប់ និងអាចជឿជាក់បាន ។

បន្ទាប់ពីបានពិនិត្យមើលគំនិតទាំងឡាយរបស់សហគមន៍ ដោយសហការជាមួយដៃគូរបស់យើងនៅ King County Metro Transit និងការសិក្សាគំរូចរាចរណ៍លើប្រព័ន្ធកុំព្យូទ័រ យើងស្នើឲ្យជ្រើសយកជម្រើសទី ១ សម្រាប់ការអនុវត្តន៍គម្រោងលើកំណាត់ផ្លូវចាប់ពីវិថី S Kenny St ទៅដល់វិថី S Henderson St ។ ជម្រើសនេះអាចត្រូវបានដាក់ឲ្យដំណើរការយ៉ាងឆាប់បំផុតនៅក្នុងរដូវស្លឹកឈើជ្រុះនៃឆ្នាំ ២០១៨* ។

យើងក៏បានពិចារណាអំពីការកែប្រែមួយចំនួននៅត្រង់ផ្លូវប្រសព្វនៃផ្លូវ S Henderson St ។ ដោយសារភាពស្មុគស្មាញនៃខ្សែភ្លើងពីលើរថយន្តក្រុងនៅត្រង់ទីតាំងនេះ យើងនឹងចំណាយពេល ១ ឆ្នាំកន្លះបន្ថែមទៀត ដើម្បីរៀបចំផែនការកែលម្អ និងស្វែងរកប្រាក់សម្រាប់ការអនុវត្តន៍គម្រោង ដើម្បីឲ្យផែនការកែលម្អនេះអាចត្រូវបានចាប់ផ្ដើមស្របពេលនឹងការចាប់ផ្ដើមនៃគម្រោងកែលម្អ RapidRide Rainier ។

ឧបត្ថម្ភគម្រោងដោយប្រាក់បានពីការប្រមូលពន្ធរយៈពេល ៩ ឆ្នាំនៃគម្រោងឈ្មោះ Levy to Move Seattle ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតនៅឆ្នាំ ២០១៥ ។ សូមអានព័ត៌មានបន្ថែមអំពីការប្រមូលពន្ធនេះដោយចូលទៅអាននៅគេហទំព័រ www.seattle.gov/LevytoMoveSeattle ។

* កាលវិភាគអាចប្រែប្រួល ។

Seattle Department of Transportation

VISION ZERØ SAFER STREETS FOR SEATTLE

The Levy to MOVE SEATTLE

## ការរំពឹងទុកមួយចំនួននៅក្នុងពេលសាងសង់

យើងរំពឹងថាការសាងសង់ចាប់ផ្តើមនៅឆ្នាំនេះ (ពោលគឺនៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៨) * ហើយប្រហែលអាចចាប់ផ្តើមនៅ ២ ឬ ៣ ចុងសប្តាហ៍ ។ ការលុបបំបាត់ថ្នាំពណ៌នៃខ្សែបន្ទាត់បែងចែកគន្លងផ្លូវ នឹងធ្វើឡើងនៅពេលយប់ រីឯការលាបថ្នាំពណ៌ និងការកែតម្រូវភ្លើងសញ្ញា នឹងធ្វើឡើងនៅពេលថ្ងៃ ។ យើងនឹងព្យាយាមកាត់បន្ថយការប៉ះពាល់ដល់សាធារណជនឱ្យបានច្រើនតាមលទ្ធភាពអាចធ្វើបាន ហើយយើងក៏សង្ឃឹមថានឹងគ្មានការបញ្ហាឲ្យសាធារណជនបើកបរតាមផ្លូវវាងដែរ ។ សូមអានសំបុត្រដែលយើងផ្ញើទៅអ្នក ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីការសាងសង់នៅរដូវក្តៅនេះ។

## ជម្រើសដែលគេបានស្នើឲ្យទទួលយក




គម្រោង Vision Zero Improvements (មើលទៅទិសខាងជើង) នឹងត្រូវបានដាក់ឲ្យដំណើរការឆាប់ៗនេះនៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៨* ចាប់ពីវិថី S Kenny St ទៅដល់វិថី S Henderson St ។

គម្រោង RapidRide Rainier នឹងសាងសង់ស្ថានីយ៍ថ្មីៗ ហើយក៏ប្រហែលអនុវត្តគម្រោងកែលម្អផ្នែកស៊ីវិលផ្សេងទៀតផងដែរ ។ យើងកំពុងបន្តតាមមើលចរាចរណ៍តាមដងផ្លូវនេះ ហើយយើងនឹងកែប្រែបន្ថែមទៀតប្រសិនបើយើងឃើញថាសមស្រប ។

### ព័ត៌មានអំពីគម្រោង និងទំនាក់ទំនង

www.seattle.gov/transportation/rainieraves.htm
James Le, គម្រោង
RainierAveS@Seattle.gov | (206) 684-3174

## សញ្ញាសម្គាល់




សញ្ញាសម្គាល់
- ដំណាក់កាលទី ១ (បញ្ចប់នៅឆ្នាំ ២០១៥)
- ដំណាក់កាលទី ២ (រំពឹងថានឹងចាប់ផ្តើមនៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៨)
- គម្រោង RapidRide Rainier Route នាពេលអនាគត (រំពឹងថានឹងចាប់ផ្តើមនៅឆ្នាំ ២០២១)